# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣

## សេចក្តីផ្តើម

ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់សុខភាពសាធារណៈ និងស្ថានភាពរស់នៅរបស់ប្រជាជន ជាពិសេស ស្ត្រី កុមារ និងជនងាយរងគ្រោះ ក្រសួងបានខិតខំប្រឹងប្រែងអនុវត្តកម្មវិធីឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និងបានកំណត់នូវចក្ខុវិស័យ "នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទត្រូវមានសេវាផ្គង់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព" ។ គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣ បានចូលរួមយ៉ាងសំខាន់ក្នុងការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទ ពង្រឹងសមត្ថភាពស្ថាប័ន លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅខេត្តគោលដៅចំនួន ១០ គឺៈ បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប កំពង់ស្ពឺ កំពត ព្រះវិហារ និងឧត្តរមានជ័យ ។

គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣ មានរយៈពេលប្រាំឆ្នាំ ដោយត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៩ និងបានចូលជាធរមាននៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០១៩ និងចាប់ផ្តើមអនុវត្តន៍សកម្មភាពចាប់ពីខែមករា ឆ្នាំ ២០២០ ហើយនឹងបិទបញ្ចប់គម្រោងនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ ដោយទទួលឥណទានសម្បទានពី ADB ចំនួន 36,9 លានដុល្លារអាមេរិក ក្នុងនោះហិរញ្ញប្បទានរបស់ ADB: 29.61 លានដុល្លារអាមេរិក ហិរញ្ញប្បទាន ឥតសំណងរបស់ ADB 4.39 លានដុល្លារអាមេរិក ថវិកាបដិភាគចំនួន 2,9 លានដុល្លារអាមេរិក ។

## I. គោលបំណង

គោលបំណងរបស់គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣ (TRWSS-SDP) គឺៈ

១. កែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតជនបទ

២. កែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មអនាម័យជនបទ

៣. ពង្រឹងសមត្ថភាពស្ថាប័ន លើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។

គម្រោងនេះមានវិសាលភាពគ្របដណ្តប់លើខេត្តចំនួន ១០ គឺ៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ សៀមរាប កំពង់ស្ពឺ កំពត ព្រះវិហារ និងឧត្តរមានជ័យ ។

គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទដំហានទី ៣ មានរយៈពេលប្រាំឆ្នាំ ដើម្បីលើកកម្ពស់សុខភាពដល់ប្រជាពលរដ្ឋក្នុងស្រុកចំនួន ១១ នៃខេត្តគោលដៅចំនួន ១០ តាមរយៈការទទួលសេវាផ្គត់ផ្គង់ទឹកស្អាត ការបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ការទទួលបានសេវាអនាម័យជនបទ និងការប្រព្រឹត្តអនាម័យជាក់ស្តែងដោយស្មើភាព និងប្រកបដោយនិរន្តរភាពឱ្យបាន ១០០ ភាគរយ ។

## II. សមាសភាគគម្រោង

**ក) សមាសភាគទី ១៖** កែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតជនបទ

**ខ) សមាសភាគទី ២៖** ការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មអនាម័យជនបទ

**គ) សមាសភាគទី ៣៖** ពង្រឹងសមត្ថភាពស្ថាប័នលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

## III. វឌ្ឍនភាពគម្រោង/សមិទ្ធផលគម្រោងសម្រេចបាន

**ក) សមាសភាគទី ១៖** ការធ្វើឲ្យប្រសើរឡើង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ជនបទ

**១- ការងារជីកស្រះសហគមន៍៖** សម្រាប់ Batch ២ ស្រះចំនួន ១៥ ត្រូវបានសាងសង់រួចរាល់ ១០០% បច្ចុប្បន្ន ក្រុមអនុវត្តគម្រោងថ្នាក់ខេត្ត និងក្រុមទីប្រឹក្សាកំពុងជំរុញឲ្យក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យជាំស្មៅ និងធ្វើរបងស្រះឲ្យរួចរាល់ឆាប់ៗ ។ សម្រាប់ Batch ៣ មានស្រះសហគមន៍ចំនួន ០៤ នៅខេត្តឧត្តរមានជ័យដែលត្រូវស្តារ គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០២២ នេះ ក្រុមហ៊ុនម៉ៅការសាងសង់បានចំនួន ៨០% ក្នុងនោះការងារជីកកាយដី ជណ្តើរបេតុង បេតុងការពារមុខទឹក និងសាងសង់អាងប្រព្រឹត្តិកម្មបានធ្វើរួចរាល់ នៅសល់ការងារបំពាក់ប្រព័ន្ធសឡាម៉ាស៊ីនបូម និងធ្វើការសាកល្បងប្រព័ន្ធអាងចម្រោះ។

**២- ការងារជួសជុលអណ្តូងខួង និងអណ្តូងលូ៖** សម្រាប់ Batch ២ ការងារជួសជុលអណ្តូងខួងចំនួន ៧១ និង Batch ៣ អណ្តូងចំនួន ១៨ បានសាងសង់រួចរាល់ ១០០%។ ហើយការងារធ្វើរបងដែលជាការចូលរួមរបស់សហគមន៍ក៏បានធ្វើរួចរាល់ដែរ ។ ការងារអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីការងារថែទាំ និងប្រើប្រាស់អណ្តូងដែលបានជួសជុលរួចក្នុង Batch ៣ ក៏បានធ្វើរួចរាល់ដោយក្រុមអនុវត្តគម្រោងខេត្ត ។

**៣- ការងារខួង និងសាងសង់អណ្តូងថ្មី៖** សម្រាប់ Batch ២ ការងារសាងសង់អណ្តូងខួងថ្មីចំនួន ៩០៩ និង Batch ៣ អណ្តូងខួងថ្មីចំនួន ៦៨៥ ត្រូវបានសាងសង់រួចរាល់ ១០០%។ រីឯការងារធ្វើរបងកំពុងធ្វើបន្តដោយសហគមន៍ ។ បច្ចុប្បន្ន ក្រុមអនុវត្តគម្រោងខេត្តកំពុងបន្តចុះអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីការថែទាំ និងប្រើប្រាស់អណ្តូងថ្មីនៅតាមភូមិគោលដៅរបស់ Batch ៣ ។

**៤- ការងារផលិតពាងត្រងទឹកភ្លៀងគ្រួសារ៖** សម្រាប់ Batch ២ ការងារផលិតពាងចំនួន ៣៦,៤១៧ ពាង និង Batch ៣ ពាងត្រងទឹកភ្លៀងចំនួន ៣៥,៣៨៨ ពាង ត្រូវបានផលិតរួចរាល់ ១០០% និងដឹកជញ្ជូនដល់ផ្ទះប្រជាពលរដ្ឋ ។

**៥- ការងារសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍៖** សម្រាប់ Batch ២ ពុំមានប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ទេ ។ សម្រាប់ Batch ៣ មានប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ០៤ ទីតាំង ដែលក្នុងនោះ នៅខេត្តព្រះវិហារមាន ១ ទីតាំង និងខេត្តកំពង់ស្ពឺមាន ០៣ ទីតាំងត្រូវបានសាងសង់រួចរាល់ ១០០%។ ការងារសាកល្បងដំណើរការប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍នេះក៏បានធ្វើរួចរាល់ និងបានត្រួតពិនិត្យត្រឹមត្រូវ ។ ការងារបណ្តុះបណ្តាល ស្តីពីការថែទាំ និងប្រតិបត្តិការប្រព័ន្ធចែកចាយទឹកនឹងត្រូវធ្វើនៅពេលដែលប្រព័ន្ធបណ្តាញទឹកខាងលើដំណើរការល្អ ។

**៦- ការងារសាងសង់ស្ថានីយផលិតទឹកពីបរិយាកាស៖** ស្ថានីយផលិតទឹកពីបរិយាកាស (Air-to-Water) ដែលមានទីតាំងនៅ ០៥ ខេត្ត គឺខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពត ក្រុមហ៊ុនម៉ៅការបានសាងសង់រួចរាល់ហើយ។ ក្រុមហ៊ុនម៉ៅការបានធ្វើតេស្តសាកល្បងពីដំណើរការប្រព័ន្ធផលិតទឹកពីបរិយាកាសទាំង ០៥ ទីតាំងរួចរាល់ហើយ ។ បច្ចុប្បន្ន ក្រុមហ៊ុនម៉ៅការ កំពុងតាមដានពីដំណើរការរបស់ម៉ាស៊ីនទាំង ០៥ ខាងលើជាបន្ត។

**៧- ការងារសាងសង់អាងត្រងទឹកភ្លៀង៖** សម្រាប់ Batch ២ អាងត្រងទឹកភ្លៀងផ្លាស្ទីក (PE) ចំនួន ៧៩ ត្រូវបានសាងសង់រួចរាល់ ១០០%។ សម្រាប់ Batch ៣ ពុំមានអាងត្រងទឹកភ្លៀងផ្លាស្ទីកទេ ។

**ខ) សមាសភាគទី ២៖** ការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាកម្មអនាម័យជនបទ

**១- ការងារសាងសង់បង្គន់គ្រួសារ៖** សម្រាប់ Batch ២ បានសាងសង់បង្គន់គ្រួសារផ្នែកខាងក្រោមបាន ១០០% ចំនួន ៥,៩២០ ក្នុងខេត្តគោលដៅទាំង ១០ ខេត្ត ។ គិតត្រឹមពេលនេះ ក្រុមការងារអនុវត្តគម្រោងថ្នាក់ខេត្ត និងទីប្រឹក្សាបានជំរុញការសាងសង់បង្គន់គ្រួសារដោយប្រើថវិកាផ្ទាល់ខ្លួននៅតាមភូមិគោលដៅក្នុង Batch ១ Batch ២ និង Batch ៣ បានចំនួន ៤,៩៤៥ បង្គន់ ។ សម្រាប់ Batch ៣ គម្រោងពុំមានបង្គន់គ្រួសារដែលត្រូវផ្តល់ជូនប្រជាជនទេ ។

**២- ការងារសាងសង់បង្គន់សាធារណៈ៖** សម្រាប់ Batch ២ បង្គន់សាធារណៈចំនួន ៦៩ ត្រូវបានសាងសង់រួចរាល់ ១០០%។ សម្រាប់ Batch ៣ ពុំមានបង្គន់សាធារណៈដែលត្រូវសាងសង់ទេ ។

**គ) សមាសភាគទី ៣៖** ពង្រឹងសមត្ថភាពស្ថាប័នលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

**១- ការអភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង និងអនុវត្តគម្រោង៖** ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ (PCU) និងក្រុមទីប្រឹក្សា (PIC) បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តគម្រោង និងក្រុមទីប្រឹក្សាថ្នាក់ខេត្តសរុបក្នុងឆ្នាំ ២០២២ ដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាល ស្តីពីការងាររៀបចំរបាយការណ៍សិក្សាគ្រប់ជ្រុងជ្រោយលើផ្នែកបរិស្ថាន និងសង្គម (EDDR and SDDR) ឲ្យបានត្រឹមត្រូវ
- វគ្គបណ្តុះបណ្តាល ស្តីពីជម្រើសសម្រាប់បង្គន់អនាម័យគ្រួសារ ការគ្រប់គ្រងកាកសំណល់លាមក និងការបង្កើតក្រុមអ្នកសន្សំប្រាក់សម្រាប់សាងសង់បង្គន់គ្រួសារ
- វគ្គបណ្តុះបណ្តាលឡើងវិញ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀន មណ្ឌលសុខភាព និងវត្តអារាម
- វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងយេនឌ័រ
- វគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការសុវត្ថិភាពទឹក ការប្រតិបត្តិ និងការថែទាំប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ និងស្រះសហគមន៍ ការគ្រប់គ្រងបរិស្ថានសម្រាប់ការងារសាងសង់សំណង់ស៊ីវិល ការធ្វើតេស្តគុណភាពទឹកនៅទីតាំងប្រភពទឹក និងការត្រួតពិនិត្យ តាមដានគុណភាពទឹក
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យព័ត៌មានសុវត្ថិភាពសង្គម និងបរិស្ថានសម្រាប់រៀបចំរបាយការណ៍សិក្សាសមិទ្ធលទ្ធភាពអនុគម្រោង និងរបាយការណ៍ផ្ទៀងផ្ទាត់សុវត្ថិភាពសង្គម និងបរិស្ថាន
- វគ្គបណ្តុះបណ្តាល ស្តីពីរបៀបអង្កេតផលប៉ះពាល់របស់ Batch ១
- វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ នៃការទទួល និងដោះស្រាយពាក្យបណ្តឹងតវ៉ារបស់ជនរងគ្រោះដែលរងផលប៉ះពាល់ដោយការអនុវត្តគម្រោង
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ និងការបំពេញប្រព័ន្ធ PPMS
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រមូល និងបង្ហាញទិន្នន័យ និងព័ត៌មានគុណភាពទឹក (Qualitative data/information)
- វគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យ តាមដានផែនការសុវត្ថិភាពទឹក និងអនាម័យ
- វគ្គបណ្តុះបណ្តាល ស្តីពីការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយទៅក្នុងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងរបៀបរៀបចំផែនការសុវត្ថិភាពទឹក និងអនាម័យសម្រាប់ឃុំ និងស្រុក
- វគ្គបណ្តុះបណ្តាល ស្តីពីផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពក្រោយ ODF
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្រ្ត (GIS) ក្នុងការរៀបចំផែនទី និងបង្កើតទិន្នន័យ (GIS) សម្រាប់អណ្តូងខួងទាំងអស់របស់គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទជំហានទី ៣ ។

**២- ការត្រួតពិនិត្យការអនុវត្តច្បាប់ការពារសុវត្ថិភាព៖**

- GRM មិនមានការរាយការណ៍អំពីបណ្តឹងតវ៉ាពីការអនុវត្តគម្រោង Batch ១ Batch ២ និង Batch ៣ ទេ ។

**៣- ផែនការសកម្មភាពយេនឌ័រ (GAP)៖**

- រៀបចំផែនការសកម្មភាពយេនឌ័រសម្រាប់គ្រប់ខេត្ត ស្រុក ឃុំ និងភូមិគោលដៅ

- ធ្វើការតាមដានការអនុវត្តផែនការសកម្មភាពយេនឌ័រ ។

❖ **ការងារលទ្ធកម្ម៖**

ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិបានរៀបចំធ្វើលទ្ធកម្ម និងផ្តល់កិច្ចសន្យាសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ សម្រាប់ Batch ៣ និង Batch ៤ រួចរាល់ ។

## IV. បញ្ហាប្រឈម

- ឆ្នាំ ២០២២ នេះខេត្តមួយចំនួនធំ ជាពិសេស ខេត្តជុំវិញបឹងទន្លេសាបទទួលរងគ្រោះដោយទឹកជំនន់ខ្លាំងដែលបណ្តាលឲ្យហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក ដូចជា អណ្តូង ស្រះសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធអនាម័យជនបទ (បង្គន់គ្រួសារ និងបង្គន់សាធារណៈ) ដែលបានសាងសង់រួចមួយចំនួនត្រូវរង់ការជនលិច និងខូចខាត។ ក្រៅពីនោះ គ្រោះទឹកជំនន់ ឆ្នាំ ២០២២ នេះក៏ធ្វើឲ្យការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទមានការយឺតយ៉ាវ ជាពិសេសការងារស្តារស្រះសហគមន៍ រីឯការងារបណ្តុះបណ្តាល និងអប់រំ ផ្សព្វផ្សាយសហគមន៍ក៏ត្រូវបានផ្អាកនៅតាមតំបន់ដែលរងការជនលិចខ្លាំងនេះផងដែរ
- ការចូលរួមវិភាគទានរបស់សហគមន៍សម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដូចជាស្រះសហគមន៍ អណ្តូងទឹក ជាដើម មានការលំបាក ដោយអ្នកទទួលផលមួយចំនួនមិនយល់ និងមិនព្រមចូលរួមវិភាគទាន ទោះបីជា ក្រុមអនុវត្តគម្រោងថ្នាក់ខេត្តបានចុះអប់រំ ណែនាំ ជាច្រើនលើកក៏ដោយ ។

## V. ទិសដៅការងារឆ្នាំ ២០២៣

សម្រាប់ទិសដៅឆ្នាំ ២០២៣ ខាងមុខ ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ ក្រុមអនុវត្តគម្រោងថ្នាក់ខេត្ត និងក្រុមទីប្រឹក្សា មានផែនការមួយចំនួនដែលនឹងត្រូវអនុវត្តមានដូចជា៖

- បន្តតាមដានការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ Batch ៣ និង Batch ៤ របស់អ្នកម៉ៅការ
- បន្តបណ្តុះបណ្តាលគ្រូបង្គោលលើផ្នែកកែប្រែទម្លាប់អនាម័យ និងផែនការសុវត្ថិភាពទឹក និងអនាម័យ
- បន្តចុះបណ្តុះបណ្តាលសហគមន៍លើផ្នែកកែប្រែទម្លាប់អនាម័យ និងផែនការសុវត្ថិភាពទឹក និងអនាម័យ
- បន្តចុះបណ្តុះបណ្តាលសហគមន៍លើផ្នែក O&M សម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតមានដូចជា អណ្តូង ស្រះសហគមន៍ និងប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍
- រៀបចំកិច្ចប្រជុំប្រចាំខែរបស់ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ ក្រុមអនុវត្តគម្រោងថ្នាក់ខេត្ត និងក្រុមទីប្រឹក្សា និងកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មការសម្របសម្រួលគម្រោង
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី ADB ។

## សេចក្តីសន្និដ្ឋាន

គិតត្រឹមខែធ្នូ ឆ្នាំ ២០២២ នេះ ការងារអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទដំហានទី ៣ បានប្រព្រឹត្តទៅតាមផែនការ យោងតាមការវាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB ទោះបីជាមានឧបសគ្គមួយចំនួន ដូចជា គ្រោះទឹកជំនន់យ៉ាងណាក៏ដោយ ។ គម្រោងនេះត្រូវបានចាត់ថ្នាក់ព័ណបៃតងដោយ ADB គឺជាគម្រោងពុំមានហានិភ័យ នៃបរាជ័យ។ ក្រុមសម្របសម្រួលគម្រោងថ្នាក់ជាតិ ក្រុមអនុវត្តគម្រោងថ្នាក់ខេត្ត និងក្រុមទីប្រឹក្សានឹងបន្តព្យាយាមប្រឹងប្រែងអនុវត្តឲ្យបានជោគជ័យតាមការគ្រោងទុកដែលនឹងបញ្ចប់នៅចុងឆ្នាំ ២០២៣ ខាងមុខ ។

**សូមអរគុណ**